Reading Book

# ពិភពរឿងនិទាន
## The World of Stories

# ជីវិតសុនីតា
# Sonita's Life



M.67

**គិតល្អ ធ្វើតែអំពើល្អ នឹងបានផលល្អ**





**សុនីតា** ចាប់តាំងពីឪពុកម្តាយស្លាប់ចោលទៅ នាងរស់នៅជាក្មេងកំព្រាកំសត់តែលតោលម្នាក់ឯង។ ថ្ងៃមួយនាងក៏បានទៅដល់ផ្ទះស្ត្រីចំណាស់ម្នាក់ជាអ្នកមានទ្រព្យសម្បត្តិ។ នាងក៏ចូលទៅសុំជូនចាស់នៅជាមួយ។ ជូនចាស់ក៏ព្រមទទួលនាង។

Since her parents passed away, Sonita became an orphan living sadly and lonely. One day, she came across the house of a wealthy old lady. She walked into the house and asked the old lady to live with her. The old lady then agreed with her imploration.

ដូនចាស់ម្នាក់នេះបានប្រើ **សូនីតា** ឱ្យធ្វើការគ្រប់បែបយ៉ាងទាំងអស់ ទាំងការងារផ្ទះបាយ ថែសួន និងរៀបចំក្នុងផ្ទះគ្រប់ទីកន្លែង។ រាល់ថ្ងៃនាងត្រូវធ្វើការជាច្រើន តែទោះជាយ៉ាងនេះក៏ដោយក៏នាងនៅតែអត់ធ្មត់តស៊ូក្នុងជីវិតរបស់នាងដែរ។



ដូនចាស់តែងតែប្រើពាក្យគំរោះគំរើយទៅលើនាង ព្រោះនាងធ្វើការអ្វីមិនគាប់ចិត្តគាត់សោះ។

The old lady ordered Sonita to do all kinds of chores such as kitchen work, gardening and preparing the household. Though she did lots of work each day, Sonita was patient and never complained. The lady always used harsh words to the girl because whatever the girl did never satisfied the lady.



ថ្ងៃមួយនៅពេលដែលនាងកំពុងរៀបចំគ្រែរបស់ដូនចាស់។ ពេលនោះដូនចាស់ក៏ដើរមកក្បែរគ្រែស្ដីឱ្យនាងខ្លាំងៗថា "នែ៎ **សុធីតា** នាងឯងនេះធ្វើការមិនប្រយ័ត្នសោះ មើលនែសុទ្ធតែសក់



អ៊ីចឹងទេតើ បានជាអញដេកមិនលក់សោះ"។ ដូនចាស់ចង្អុលមុខនាងដោយខឹងយ៉ាងខ្លាំង"។



One day when Sonita was making the lady's bed, the old lady walked towards her and said loudly and roughly. "Sonita!" the old lady said, "how carelessly you work! Here's hair all over the bed. I have never slept well because of it." The lady furiously pointed her finger at Sonita's face.



ក្រោយមកដូនចាស់បានបណ្ដេញ **សូនីតា** ឱ្យចាកចេញពីផ្ទះរបស់គាត់។ ជីវិតនាងពេលនេះប្រៀបដូចជាចកដែលរសាត់គ្មានទីជម្រក។

Afterwards, the old lady kicked out Sonita from her house. Then, Sonita's life was like a plant floating on water without landing.



នាងដើរកាត់ពីភូមិមួយទៅភូមិមួយបានទៅដល់ផ្ទះប្តីប្រពន្ធពីរនាក់ ជាអ្នកលក់សំភារកសិករ។ ម្ចាស់ផ្ទះនោះពុំមានកូនមួយនាក់ឡើយ។ នាងបានសុំជួយលក់កសិករ ហើយពួកគាត់បានស្រុះស្រួលគ្នាឱ្យនាងរស់នៅជាមួយ ហើយចិញ្ចឹមនាងរហូតដល់ធំ មិនតែប៉ុណ្ណោះ ពួកគាត់ស្រឡាញ់នាងដូចកូនបង្កើតទៀតផង។ ក្រោពីការសិក្សា **សូនីតា** បានជួយធ្វើការឱពុកម្តាយចិញ្ចឹមគ្រប់បែបយ៉ាង និងជួយលក់ដូរនៅផ្ទះផងដែរ។

Sonita walked from one village to another and eventually arrived at the house of husband and wife who sold farming tools to earn a living. The couple did not have any children. Sonita asked them to help sell the tools.



The couple agreed to let her live with them and promised to take care of her until she grew up. Moreover, they loved Sonita and regarded her as their daughter. In addition to her study, Sonita helped her parents do every work and sell something in the house.



និយាយពីជូនចាស់ម្នាក់នោះវិញ ចាប់តាំងពីអត់ពី **សូនីតា** ទៅ គាត់ត្រូវធ្វើការសព្វបែបយ៉ាងទាំងអស់។ ដោយសារគាត់ជាមនុស្សចាស់ គាត់ក៏ធ្វើការភ្លេចមុខភ្លេចក្រោយ។ ថ្ងៃមួយពេលដែលគាត់ធ្វើការមិនបានប្រយ័ត្នក៏បណ្តាលឱ្យមានភ្លើងឆេះផ្ទះគាត់ បាត់បង់ផ្ទះសំបែង អស់ទាំងទ្រព្យសម្បត្តិសល់តែខ្លួនមួយគ្មានទីពឹង។ ដោយអស់ជំរើសក្នុងជីវិត គាត់ក៏ដើរសុំទានគេសម្រាប់ចិញ្ចឹមជីវិត។

Talking about the old lady, since Sonita left, she had to do every work. Because of her old age, she was very forgetful. One day, owing to her carelessness, she caused her house burn down. She became homeless, lost wealth and lived independently. Feeling hopeless and having no choice in her life, she became a beggar.







នៅល្ងាចថ្ងៃមួយ ដូនចាស់ក៏ដើរមកដល់ផ្ទះ លក់សំភារកសិករហើយនិយាយជាមួយ **សូនីតា** តាមរបៀបអ្នកសុំទាន។ **សូនីតា** ស្គាល់ជាក់ជាដូនចាស់ ក៏និយាយគួរសមហើយដាក់ទានម្ហូបអាហារមកជូនគាត់ពិសា។ ដោយឃើញគាត់ជាមនុស្សចាស់ជរា ហើយមេឃក៏កាន់តែងងឹតផងនោះ នាងក៏អង្វរឪពុកម្ដាយសុំឱ្យឃាត់ដូនចាស់ ឱ្យសម្រាកនៅផ្ទះនេះបានមួយយប់។ ឪពុកម្ដាយក៏យល់ស្របតាមគំនិតរបស់កូនមិនជំទាស់អ្វីទេ ។

One evening, the old day wandered and arrived at the house of the farmers whom she lived with. She talked to Sonita in a begging manner. Recognizing the old lady, Sonita said to her politely and gave her food. Seeing that the lady was very old and that it was getting dark, Sonita asked for permission from her parents to let the old lady stay overnight. The parents agreed to their daughter's request without saying anything.



**សុធីតា** បាននិយាយទៅកាន់ដូនចាស់ថា "លោកយាយផ្ទះខ្ញុំចង្អៀតបន្តិចហើយ ព្រោះមានអីវ៉ាន់ច្រើនណាស់"។



ជូនចាស់ឆ្លើយថា "ចៅហ្នា ! ឱ្យយាយដេក ក្នុងបន្ទប់ដាក់អីវ៉ាន់នេះចុះ យ៉ាងណាៗ ក៏គ្រាន់បើជាងដេកតាមចិញ្ចើមថ្នល់ដែរ ណាចៅ"។ នាងឆ្លើយថា "អ៊ីចឹង តាមចិត្តលោកយាយចុះ"។ ហើយពួក គាត់ក៏ចូលសម្រាករៀងៗខ្លួនទៅ។

"Grandma!" Sonita said to the old lady, "my house has little space because it is loaded with lots of farming tools." The old lady replied, "Granddaughter! Let me stay in this storage room. It's much better than sleeping on the pavement." Sonita said, "Up to you, grandma." Then they went to bed respectively.

លុះព្រឹកឡើង **សុនីតា** ក៏រៀបចំអីវ៉ាន់លក់ដូចធម្មតា។ នាងសួរទៅជូនចាស់ថា "លោកយាយ ! យប់មិញសម្រាន្តលក់ទេ"។ យាយផ្តល់ចម្លើយថា "អើ ! យាយដេកលក់ស្រួលណាស់ណាចៅ។ យាយអរគុណចៅខ្លាំងណាស់ដែលមានចិត្តសប្បុរសចំពោះយាយ"។

Next morning, Sonita prepared for the sale as she usually did. "Could you sleep last night?" Sonita asked the old lady. "Yes. I slept very well, granddaughter," the old lady replied. "Thank you very much for your kindness and generosity."







**សុនីតា** ចម្លែកក្នុងចិត្តណាស់ ព្រោះដូនចាស់ម្នាក់នេះកាលពីមុន សូម្បីតែសម្រាន្តលើសក់ពីរ-បីសរសៃក៏គាត់ថាសម្រាន្តមិនលក់ដែរ ចុះហេតុអ្វីក៏គាត់សម្រាន្តលើខ្សែគោនេះបាន"។ តែទោះជាបែបនេះក៏ដោយ ក៏នាងមិនប្រកាន់ខឹងនឹងគាត់ដែរ ព្រោះនាងយល់ថា ដូនចាស់ម្នាក់នេះធ្លាប់ចិញ្ចឹមនាងមួយរយៈកន្លងមក នាងក៏បានអង្វរឪពុកម្ដាយសុំឱ្យដូនចាស់រស់នៅជាមួយ ព្រោះឃើញគាត់ចាស់ណាស់ទៅហើយ។ **ចប់**

Sonita was quite amazed: previously the old lady had always said she couldn't sleep with only few wisps of hair. Why could she sleep well on such cattle-tying strings? However, Sonita was not angry with the old lady because she thought that this lady used to nourish her, so she asked for permission from her parents to permit the old lady to live in the house because she thought that the lady was getting old. **The End**

## សំណួរ

១-តើជូនចាស់ជាមនុស្សដែលមានចរិកដូចម្ដេច?

២-ហេតុអ្វីបានជាសូនីតាសុំជូនចាស់នៅជាមួយ?

៣-តើសូនីតាបាននៅជាមួយជូនចាស់រហូតដែរឬទេ? ព្រោះអ្វី?

៤-តើវាសនារបស់សូនីតាបានទៅជួបអ្នកណា? ប្រកបមុខរបរអ្វី? តើនាងមានឱកាសបានសិក្សាដែរឬទេ?

៥-ជូនចាស់បានធ្វើទណកម្មលើកុមារីសូនីតា ចុងក្រោយ តើជូនចាស់ក្លាយជាមនុស្សបែបណា?

## Questions:

1. What was the old lady like?
2. Why did Sonita ask to live with the old lady?
3. Did Sonita live with the old lady forever? Why?
4. Who did Sonita come across? What did they do? Did she have a chance to go to school?
5. The old lady treated badly to Sonita. Finally, how was the old lady's life?

**ពេលនៅគួរឱ្យស្រឡាញ់ ចេញទៅវិញគួរឱ្យស្រណោះ**